# ត្រូវរួមគ្នា
# ជួយសង្គ្រោះជាតិយើង

ដោយ Jasmine Kc ថ្ងៃទី១២ កក្កដា ២០១៣




១. បើជាតិលិចលង់ភ័យន្តរាយ   រាស្ត្រខ្មែរគ្រប់កាយជួយសង្គ្រោះ
រួមចូករួមថៃវ ចុកធ្លាយធ្លុះ   ទើបនាវាឆ្ពោះដល់ត្រើយសុខ។
២. គឺរាស្ត្រនេះហើយម្ចាស់ប្រទេស   ចូរកុំទ្វេធ្វេស គិតភូមិស្រុក
ឆ្មៀងសង្កេតការណ៍នៅនឹងមុខ   កុំគេចរកសុខមិនខ្វល់ជាតិ។
៣. អ្នកគឺកោសិកាសង្គម   ប្រទេសទុក្ខធំគួរខ្មីឃ្មាត
ជួយស្រង់ជួយស្រោចឥតរវាត   រួមជាផៅញាតិគ្រួសារខ្មែរ។
៤. ម្នីះខ្មែរខ្លះៗ អាត្មានិយម   គិតភាពសុខដុមបក្សពួកខ្សែ
បូមបារកិបកេង ឥតខ្វល់ទេ   នគរស្ទើរតែដួលរលំ។
៥. បើអ្នកមានខួរ គួរចេះគិត   វិចារណញ្ញាណបិតគិតសង្គម
បើអ្នកជាខ្មែរកត្តញ្ញូចំ   រួបរួមមូលផ្តុំសង្គ្រោះជាតិ។
៦. ធ្វើជាមនុស្សប្រសើរក្តាត់   ល្អល្អះជាងសត្វម្រឹគឯទៀត
ចូរមានសម្បជញ្ញៈភ្ញាក់ជួយជាតិ   សាវតារចារខ្មាតពង្សអង្គរ។
៧. ប្រទេសស្ថិតក្នុងគ្រោះមហន្តរាយ   ច្នេះខ្មែរគ្រប់កាយក្រោកឈូឆរ
រួមជាធ្លុងមួយស័ព្ទខ្មាខ្មួរ   ការពារភូមិករគ្រួសារខ្មែរ។
៨. ជយោ កម្លាំងខ្មែរក្លាហាន.,!   ក្រោកគ្រប់ភូមិឋាន ឥតងាករេ
ជ្រោងទង់សាមគ្គី អង្គរខ្មែរ   ទើបជាតិស្ថិតស្ថេរគង់វង្សបាន៕